អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងជូនដំណឹងពីសាលក្រមពេញលេញជាលាយលក្ខណ៍អក្សរ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង នៅក្នុងសំណុំរឿង ០០២/០២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) បានជូនដំណឹងអំពីសាលក្រមពេញលេញជាលាយលក្ខណ៍អក្សររបស់ខ្លួន នៅក្នុងសំណុំរឿង ០០២/០២ ជាភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង ពាក់ព័ន្ធនឹងជនជាប់ចោទ **នួន ជា** និង **ខៀវ សំផន**។

សាលក្រមនៃសំណុំរឿង ០០២/០២ គឺជាសាលក្រមវែងជាងគេបំផុត ដែល អ.វ.ត.ក. បានចេញរហូតដល់ពេលនេះ ដោយសាលក្រមនេះមានទំហំរួមទាំងឧបសម្ព័ន្ធជាភាសាខ្មែរចំនួន **៤១០១ ទំព័រ** ជាភាសាអង់គ្លេសចំនួន **២៣៨៧ ទំព័រ** និងជាភាសាបារាំងចំនួន **២៨២៨ ទំព័រ**។

ភាសាខ្មែរ https://www.eccc.gov.kh/km/document/court/saalkrmsmnnumryang-00202

ភាសាអង់គ្លេស https://www.eccc.gov.kh/en/document/court/case-00202-judgement

ភាសាបារាំង https://www.eccc.gov.kh/fr/document/court/jugement-rendu-lissue-du-deuxieme-proces-dans-le-cadre-du-dossier-no-002

សវនាការដេញដោល ពិនិត្យភស្តុតាង នៅក្នុងការជំនុំជម្រះក្តីសំណុំរឿង ០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ហើយបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ នៅក្នុងអំឡុងពេលជំនុំជម្រះក្តីនេះ អង្គជំនុំជម្រះបានស្តាប់សក្ខីកម្មបុគ្គលចំនួន ១៨៥ នាក់ រួមមាន សាក្សី ១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណី ៦៣ នាក់ និងអ្នកជំនាញ ៨ នាក់។ មូលដ្ឋានភស្តុតាងនៅក្នុងសំណុំរឿង ០០២/០២ រួមមានឯកសារជាង ១០.៨០០ ឯកសារ សម្រាប់អង្គជំនុំជម្រះសាលាដំបូងធ្វើការវិភាគនិងពិចារណាសម្រេច។

នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសេចក្តីសង្ខេបនៃសំអាងហេតុនិងផ្នែកសម្រេចសេចក្តីរបស់ខ្លួន នៅក្នុងសំណុំរឿង ០០២/០២ ជាសាធារណៈ នៅសាលសវនាការធំរបស់ អ.វ.ត.ក. ហើយបានសម្រេចផ្តន្ទាទោសជនជាប់ចោទទាំងពីរនាក់ដាក់ពន្ធនាគារអស់មួយជីវិត។

សេចក្តីសង្ខេបនៃសាលក្រមអាចចូលពិនិត្យមើលបានតាមរយៈគេហទំព័រ អ.វ.ត.ក. ខាងក្រោមនេះ៖
https://www.eccc.gov.kh/km/document/court/saalkrmsngtthepsmnnumryang-00202-baakbndhnyngjnjaapcood-nuan-jaa-ningkhiev-smphn

សម្រាប់ព័ត៍មានបន្ថែម សូមទាក់ទង៖

**លោក នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងមន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម

ទូរសព្ទដៃ៖ +៨៥៥ (0) ១២ ៤៨៨ ១៥៦

អ៊ីមែល៖ neth.pheaktra@eccc.gov.kh